**ស្ថានទូតជប៉ុន**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

**សេចក្តីប្រកាសព័ត៌មាន**

លេខ.16 PR-20/EoJ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០

# ជប៉ុនផ្តល់ ៨៩០,៤៧១ ដុល្លារអាមេរិក សម្រាប់ការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ សុខភាពមាតានិងទារកនិងអនាម័យ និងការកសាងសមត្ថភាពយុវជន

រដ្ឋាភិបាលជប៉ុន បានឯកភាពផ្តល់ថវិកាសរុបចំនួន ៨៩០,៤៧១ ដុល្លារអាមេរិក ដល់អង្គការចំនួនបីក្រោមគ្រោងការណ៍ជំនួយហិរញ្ញប្បទានឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ**ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងអង្គភាពទទួលជំនួយទាំងបី សម្រាប់គម្រោងដូចតទៅ៖

១. <u>គម្រោងសាងសង់អាងស្តុកទឹកសម្រាប់លើកកម្ពស់កសិកម្មនៅព្រះវិហារ-ភូមិធម្មជាតិសម្តេចតេជោ (ថវិកាចំនួន៨៥,០១៩ ដុល្លារអាមេរិក)</u>

<u>អង្គភាពទទួលជំនួយ៖ អង្គការមោទនភាពអាស៊ី សមាគមន៍មិត្តព្រះវិហារ-ជប៉ុន</u>

ក្នុងគម្រោងនេះមោទនភាពអាស៊ីសមាគមន៍មិត្តព្រះវិហារ-ជប៉ុននឹងជួយសាងសង់អាងស្តុកទឹកនិងបរិក្ខារចែកចាយទឹកនៅក្នុងភូមិអេកូខេត្តព្រះវិហារ។ កសិករនៅក្នុងតំបន់នេះនឹងទទួលបានអត្ថប្រយោជន៍ដោយបង្កើនផលិតកម្មកសិកម្មនារដូវប្រាំង និង រៀនពីបច្ចេកវិទ្យាកសិកម្មព្រមទាំងការគ្រប់គ្រងបរិក្ខាសម្រាប់ការអភិវឌ្ឍក្នុងតំបន់ប្រកបដោយនិរន្តរភាព។

<u>២.គម្រោងការរួមបញ្ចូលគ្នា សុខភាព អាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យក្នុងខេត្តព្រះវិហារ (ឆ្នាំទី១) (ថវិកាចំនួន ៥៥២,៤២៧ ដុល្លារអាមេរិក)</u>

<u>អង្គភាពទទួលជំនួយ៖ អង្គការ World Vision Japan</u>

ក្នុងគម្រោងនេះអង្គការនឹងផ្តល់ការបណ្តុះបណ្តាលនិងការអប់រំសុខភាពដល់បុគ្គលិកសុខាភិបាលនិងសហគមន៍មូលដ្ឋានដើម្បីកែលម្អស្ថានភាពសុខភាពមាតានិងទារកនៅស្រុកចំនួន៤ក្នុងខេត្តព្រះវិហារ។ អ្នកទទួលផលនឹងអាចផ្លាស់ប្តូរទម្លាប់នៃការញ៉ាំ ដោយមានចំណេះដឹងនិងមានលទ្ធភាពទទួលបានទឹកស្អាត។

**<u>៣. គម្រោងការកសាងសមត្ថភាពយុវជនក្នុងខេត្តប៉ៃលិន តាមរយៈការពង្រឹងមជ្ឈមណ្ឌលសិក្សាសហគមន៍ (ឆ្នាំទី១) (ថវិកាចំនួន៣៥៣,០២៥ ដុល្លារអាមេរិក)</u>**
**<u>អង្គភាពទទួលជំនួយ៖ អង្គការកុមារឥតព្រំដែន</u>**

នៅក្នុងគម្រោងនេះអង្គការនឹងគាំទ្រដល់យុវជន ជាពិសេសអ្នកដែលស្ថិតក្នុងស្ថានភាពដែលមានការងារមិនជាប់លាប់ ខ្វះជំនាញជីវិត និងបោះបង់ការសិក្សា។ តាមរយៈការផ្តល់នូវមាតិកាបណ្តុះបណ្តាលវិជ្ជាជីវៈនិងបរិបទនៃមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលល្អប្រសើរដល់យុវជន ពួកគេនឹងទទួលបានការអប់រំឬជំនាញសម្រាប់បង្កើតមូលដ្ឋានគ្រឹះនៃជីវិតកាន់តែប្រសើរនាពេលអនាគត។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពអង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២ មករដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង៣៩លានដុល្លារអាមេរិក ដល់គម្រោងចំនួន១២៥ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*